**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
លេខ: ០៣០/០៨ របក អ.គ.គ

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៨*

# របាយការណ៍ ស្តីពីកិច្ចប្រជុំក្រុមការងារជាន់ខ្ពស់ប្រព័ន្ធសូចនាករ និងការតាមដាន សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ នៅសណ្ឋាគារអាំងទ័រកុងទីណុងតាល់

ឆ្នាំពីរពាន់ប្រាំបី ខែតុលា ថ្ងៃទីប្រាំបី វេលាម៉ោងប្រាំបីកន្លះព្រឹក នៅសាលប្រជុំសណ្ឋាគារអាំងទ័រកុងទីណុងតាល់ រាជធានីភ្នំពេញ មានរៀបចំសិក្ខាសាលាមួយក្រោមអធិបតីភាពរបស់ឯកឧត្តម ស៊ុយ ម៉ុងលាង នាយកអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ និងជាតំណាងឯកឧត្តមប្រធាន ក្រុមការងារជាន់ខ្ពស់ ដើម្បីពិនិត្យ និងពិភាក្សាលើគោលការណ៍នៃការរៀបចំប្រព័ន្ធសូចនាករ និងការតាមដានសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ ។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់មកជាមួយ ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម ស៊ុយ ម៉ុងលាង បានសម្តែងនូវកិច្ចស្វាគមន៍ចំពោះអង្គសិក្ខាសាលាទាំងមូល ។ ជាបន្ទាប់ឯកឧត្តមប្រធានបានបង្ហាញជូនអំពីគោលបំណងនៃកិច្ចប្រជុំក្រុមការងារជាន់ខ្ពស់ និងអំពីដំណាក់កាលនៃការរៀបចំប្រព័នសូចនាករ និងការតាមដាននេះ ។ ដំណាក់កាលទី១ គឺជាការរៀបចំទស្សនទាន Concept ដំណាក់កាលទី២ គឺជាដំណាក់កាលនៃការអនុវត្តនូវអ្វីដែលបានដាក់ចុះ និងការតាមដានការអនុវត្ត ។ ឯកឧត្តមបានជម្រាបផងដែរថា ក្រុមការងារជាន់ខ្ពស់បានជួបប្រជុំគ្នាម្តងរួចមកហើយ ហើយឥឡូវនេះយើងបាន ឈានទៅដល់ការរៀបចំឯកសារពាក់ព័ន្ធ ដើម្បីដាក់ជូនក្រុមការងារជាន់ខ្ពស់ដើម្បីពិនិត្យ និងសម្រេចនាថ្ងៃនេះ។

ឯកឧត្តមបានបញ្ជាក់ថា ប្រព័ន្ធសូចនាករ នេះមិនមែនអនុវត្តចំពោះតែការវាស់វែងទៅលើប្រព័ន្ធតុលាការតែមួយនោះទេ គឺសម្រាប់វាស់វែងលើសកម្មភាពទាំង៩៧ របស់កំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ទាំងមូលដែលនៅក្នុងនោះក៏មានគម្រោងពាក់ព័ន្ធនឹងតុលាការដែរ ។

បន្ទាប់មកឯកឧត្តមប្រធានបានស្នើសុំអោយឯកឧត្តម សួង លាងហៃ នាយករងអង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ និងជាប្រធានក្រុមការងារបច្ចេកទេស ប្រព័ន្ធសូចនាករ ធ្វើបទបង្ហាញពីទស្សនាទានប្រព័ន្ធសូចនាករ និងការតាមដាន ជូនអង្គប្រជុំ។

ឯកឧត្តម សួង លាងហៃ បានមានប្រសាសន៍ថា គោលបំណងនៃការប្រជុំនាថ្ងៃនេះ គឺចង់អោយក្រុម ការងារជាន់ខ្ពស់ធ្វើការពិនិត្យពិភាក្សា និងផ្តល់ការយល់ព្រមទៅលើឯកសារដែល បានរៀបចំជូនសមាជិកម្នាក់ៗរួចមកហើយនោះ ក៏ដូចជាទៅលើគោលការណ៍នៃការរៀបចំសូចនាករ និងការតាមដានជារួម ។ ឯកឧត្តមបាន ធ្វើការបង្ហាញជូនអំពីការអភិវឌ្ឍន៍ប្រព័ន្ធសូចនាករ និងការតាមដាន ដែលមានចំណុចសំខាន់ៗដូចជា សារតា បរិបទ គោលការណ៍ និងមុខព្រួញនៃ ការអភិវឌ្ឍន៍ តាមរយៈឯកសារដែលបានចែកជូនអង្គប្រជុំរួចជាស្រេច។ ឯកឧត្តមបានលើកបញ្ជាក់ថានេះ គឺជាការរៀបចំសូចនាករសម្រាប់វាស់វែងតាមដានការអនុវត្តសកម្មភាពទាំង ៩៧ នៃទិសដៅជាយុទ្ធសាស្រ្តទាំងប្រាំពីរនៃ កម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្រ្តកំណែទម្រង់ច្បាប់ និងតុលាការ ។ ដំណាក់កាលទី១នេះ គឺសម្រាប់វាស់វែង ភាពជឿនលឿន ក៏ដូចជាសម្រាប់តាមដានការអនុវត្ត ការងាររបស់ក្រសួង ស្ថាប័ន ពាក់ព័ន្ធនៃវិស័យផងដែរ ។ សូចនាករ សម្រាប់វាស់វែងលទ្ធផលរំពឹងទុក ( Outcome/Result Indicators ) និងអនុវត្តក្នុងដំណាក់កាលជាបន្ត ហើយអាចចាប់ផ្តើមពីគម្រោងតុលាការគំរូ ដើម្បីឈានជាបន្តបន្ទាប់ទៅធ្វើការវាស់វែងផលប៉ះពាល់នៃកំណែទម្រង់ច្បាប់ និងតុលាការ ទាំងមូលក្នុងពេលវេលាដ៏សមស្របណាមួយ ។ ដើម្បីបង្ហាញជូនអង្គប្រជុំអោយបានយល់ច្បាស់ពីគោលការណ៍នៃការរៀបចំ សូចនាករ ឯកឧត្តមបានប្រគល់វេទិកាជូនជាបន្តទៅលោក ឃ្លោក ដារ៉ា ។

លោក ឃ្លោក ដារ៉ា ប្រធានក្រុមគម្រោងសិទ្ធិមនុស្ស និងមជ្ឈត្តកម្មនៃអង្គភាពគ្រប់គ្រង គម្រោងនៃក្រុម ប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ និងជាលេខាធិការនៃក្រុមការងារបច្ចេកទេស ប្រព័ន្ធសូចនាករបានធ្វើបទបង្ហាញអំពីការរៀបចំសូចនាការ និងការតាមដានអំពីវិធីសាស្រ្ត និងអំពីគំរូ ស្តង់ដារសូចនាករតាមដាន ។

ឯកឧត្តម ស៊ុយ ម៉ុងលាង បានបញ្ជាក់បន្ថែមថា ការវាស់វែងភាពជឿនលឿន នៃការអនុវត្តសកម្មភាព គឺធ្វើពីក្រោមឡើងទៅលើពីជំហាននីមួយៗពីសកម្មភាពនីមួយៗ ទៅសកម្មភាពទាំង ៩៧ រហូតទៅដល់ទិសដៅ ជាយុទ្ធសាស្រ្តទាំង៧ តើបានប៉ុន្មានភាគរយ ? ហើយតើយើងត្រូវធ្វើដំណើររបៀបណា ? ដំបូងគឺយើងត្រូវយក សកម្មភាពមួយមកវិភាគ ដើម្បីឱ្យដឹងថា តើក្នុងសកម្មភាពមួយនេះមានប៉ុន្មានជំហាន ដើម្បីសម្រេចអោយចេញ ជាលទ្ធផលមួយនោះ? ហើយបន្ទាប់មកទៀតយើងបន្តទៅក្នុងយុទ្ធសាស្រ្ត រួចទៅទិសដៅជាយុទ្ធសាស្រ្តនីមួយៗ ទីបញ្ចប់បូកសរុបទៅដល់សកម្មភាពទាំងអស់នៃកម្មវិធីតែម្តង។

លោកស្រី Momo Hotta តំណាង Jicaបានមានប្រសាសន៍ថា ខណៈនេះ យើងបានយល់ដឹងពីទស្សនាទាន និងពីគោលការណ៍នៃការរៀបចំសូចនាករតាមដានតាមរយៈ ការពន្យល់លំអិតរបស់ក្រុមការងារ ។ លោកស្រីបានឆ្លៀតក្នុងឱកាសនោះដែរ ចោទជាសំណួរចំនួនបួនចំណុច គឺ ៖

១-តើរយៈពេលយូរ និងញឹកញាប់យ៉ាងណាដែលយើង ត្រូវពិនិត្យតាមដានសកម្មភាព ទាំង ៩៧ នោះ ? តើអ្នកណាជាអ្នកទទួលខុសត្រូវ ? ហើយត្រូវរាយការណ៍ទៅខាងណា ?

២-ទាក់ទងនឹងសកម្មភាពរយៈពេលខ្លីក្នុងឯកសារចាស់គឺហួសពេលទៅហើយ ដូច្នេះតើយើងគួរកំណត់ រយៈពេល ខ្លី មធ្យម និងវែងនោះឡើងវិញបែបណាវិញ ?

៣-តើអ្នកណាជាអ្នកសម្រេចថា សកម្មភាពណាមួយនោះមានប៉ុន្មានជំហាន ហើយអ្នកណាខ្លះជាអ្នកទទួលខុសត្រូវ ?

៤-តើរយៈពេលប៉ុនណាសម្រាប់ជំហាននីមួយៗ? លោកស្រីក៏ទទួលស្គាល់ដែរថា វាមានការលំបាកក្នុងការកំណត់ជំហានពីព្រោះមានការស្មុគស្មាញច្រើន ។

ជាចុងក្រោយលោកស្រីបានវាយតម្លៃថា សូចនាករតាមដានដែលក្រុមការងារ បានរៀបចំជាទូទៅគឺល្អហើយយើងគួរប្រើ IMS នេះជាឧបករណ៍មួយសម្រាប់ពិនិត្យមើល ចន្លោះប្រហោងនៃការអនុវត្តផែនការក្នុងចន្លោះ ពេលនៃការប្រជុំក្រុមការងារបច្ចេកទេសម្តងៗ ។

ឯកឧត្តម ស៊ុយ ម៉ុងលាង បានមានប្រសាសន៍ឆ្លើយតបនឹងសំណួរទី១ខាងលើថា ខាងរាជរដ្ឋាភិបាល បានសម្រេចយករៀងរាល់បីខែម្តង ក្នុងការធ្វើរបាយការណ៍ ។ ចំពោះសំណួរទី២វិញ ឯកឧត្តមប្រធានបានបញ្ជាក់ថា ការកំណត់រយៈពេលខ្លីគឺកំឡុងពេលមួយឆ្នាំ ទៅមួយឆ្នាំកន្លះ រយៈពេលមធ្យម គឺ ៣ឆ្នាំ និងរយៈ ពេលវែង គឺ លើសពីបីឆ្នាំ ។ ទាក់ទងទៅនឹងសំណួរទី៣ ឯកឧត្តមប្រធាន បានមានយោបល់ថា ការទទួលខុសត្រូវ គួរតែមានការទទួលខុសត្រូវរួមគ្នា គឺក្រុមការងារដែលបានបង្កើតឡើងនេះហើយដែលជាអ្នកទទួលខុសត្រូវរួមទាំងអស់គ្នា ។ ចំពោះសំណួរទី៤ គឺបញ្ហារយៈ ពេលនោះ ឯកឧត្តមបានមានប្រសាសន៍ថា មិនអាចកំណត់បានទេ គឺអាស្រ័យទៅលើការងារនេះតែម្តង ។

ឯកឧត្តមបានបញ្ជាក់បន្ថែមទៅលើភាពជាអ្នកទទួលខុសត្រូវថា បញ្ហានេះគឺបិតនៅលើក្រុមប្រឹក្សាផ្ទាល់ជាអ្នកទទួលខុសត្រូវ ប៉ុន្តែក៏ត្រូវមានការចូលរួមពីក្រសួងស្ថាប័ន ពាក់ព័ន្ធផងដែរដែលជាអ្នកផ្តល់ព័ត៌មាន ។ ហេតុនេះហើយ បានជាយើងបង្កើតក្រុមការងារ IMS នេះគឺដើម្បីសម្រាប់មើលការខុសត្រូវ និងធ្វើការងារនេះតែម្តង ។ ឆ្លៀតពេលនោះដែរ ឯកឧត្តមបានស្នើសុំអោយដៃគូពាក់ព័ន្ធចូលរួមសហការគ្នាអោយបានពេញទំហឹង ផងដែរ ។

លោក Tomas, DIHR បានឯកភាពនឹងយោបល់របស់លោកស្រីតំណាងអោយអង្គការ Jica ដែលបាន លើកឡើងពីបញ្ហាលំបាកក្នុងការកំណត់ពេលវេលារបស់ជំហាននីមួយៗ និងការទទួលខុសត្រូវក្នុងការតាមដាន នោះដែរ ។

លោក កុយ នាម បានកោតសរសើរបុគ្គលិក PMU ដែលបានរៀបចំប្រព័ន្ធ IMS បានល្អប្រសើរសម្រាប់ធ្វើការតាមដាននេះ ។ លោកបានជូនជាយោបល់ថា ក្នុងការកំណត់ជំហាននីមួយៗ យើងគួរគិតដល់បញ្ហាហានីភ័យ ហេតុនេះហើយ យើងគួរមានយន្តការមួយសម្រាប់ធ្វើការតាមដានហានីភ័យនេះ ។

ឯកឧត្តម ស៊ុយ ម៉ុងលាង បានលើកឡើងអំពីហានីភ័យដោយមានយោបល់ថា ការបង្កើតយន្តការមួយទៀតនេះ អាចនាំអោយស្មុគ្រស្មាញទៅវិញទេ ។

ឯកឧត្តម សួង លាងហៃ បានធ្វើការបំភ្លឺពាក់ព័ន្ធទៅនឹងហានីភ័យរបស់គម្រោងនេះថា បញ្ហាចង់បង្កើតក្រុមការងារឬយន្តការនេះ គឺអាស្រ័យលើដៃគូពាក់ព័ន្ធ ដែលជាអ្នកគាំទ្រទាំងផ្នែកថវិកា និងបច្ចេកទេស ប៉ុន្តែជាធម្មតាក្នុងការរៀបចំផែនការសម្រាប់អនុវត្តគម្រោងអ្វីមួយនោះ បញ្ហាហានីភ័យតែងតែត្រូវបានគិតគូររួចស្រេច ទៅហើយ ។

តំណាង Danida មានមតិខ្លីថា ក្នុងការវាស់ភាពជឿនលឿនរបស់កំណែទម្រង់ច្បាប់ និងតុលាការយើង គួរស្វែងយល់ថា តើមានកត្តាអ្វីខ្លះដែលទប់ស្កាត់ និងរាំងស្ទះដល់ការរីកចំរើន ហើយបញ្ហានេះយើងគួរធ្វើការទាក់ទងទៅក្រសួងស្ថាប័នអ្នកអនុវត្តផ្ទាល់ ។

តំណាង USAID បានបញ្ជាក់ពីឆន្ទៈក្នុងការជួយគាំទ្រដល់កម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការរបស់រាជរដ្ឋាភិបាល ដោយបានជម្រាបជូនអំពីការបន្តកិច្ចសន្យាជាមួយអង្គការ EWMI ចំនួន ៥ឆ្នាំទៅមុខទៀតហើយលោកបានសួរថា តើត្រូវធ្វើដូចម្តេចអំពីបញ្ហាប្រមូលទិន្នន័យក្នុងការកែទម្រង់ ដើម្បីអោយមានដំណើររីកចំរើនទៅមុខ ?

ឯកឧត្តម ស៊ុយ ម៉ុងលាង បានមានប្រសាសន៍ថា ប្រព័ន្ធ IMS គឺដើម្បីវាស់នូវភាពជឿនលឿនរបស់សកម្មភាពនីមួយៗ យើងបានគោរពទៅតាមកាលបរិច្ឆេទដែលបានដាក់ ហើយបើសិនជាមិនមាន ការវិវត្តទៅមុខ តាមកាលកំណត់នោះទេ យើងនឹងធ្វើការពិចារណាហើយអាចរំកិលកាលបរិច្ឆេទទៅមុខទៀត ។

តំណាង UNDPបានមានសំណួរដែលទាក់ទងនឹងគម្រោង IMS ថា តើយើងអាចពិនិត្យ ពិភាក្សាគម្រោង IMS នេះ ជាមួយនឹងគម្រោង MBPI បានដែរឬទេ ?

ឯកឧត្តម សួង លាងហៃ បានមានប្រសាសន៍ថា រាល់គម្រោងទាំងអស់ដែល PMU រៀបចំឡើងគឺសុទ្ធតែយោងទៅរកគម្រោងឬកម្មវិធីឯទៀតៗរបស់រាជរដ្ឋាភិបាលដែលមានការពាក់ព័ន្ធ ហើយប្រសិទ្ធិ-ភាព នៃការអនុវត្តគម្រោងទាំងអស់ក៏ដូចជា គម្រោង IMS នេះ គឺទាក់ទងជាសំខាន់ទៅនឹងប្រាក់ឧបត្ថម្ភដូច្នេះគម្រោង IMS ត្រូវតែផ្សារភ្ជាប់ទៅនឹងគម្រោង MBPI នេះ ។

ឯកឧត្តម ជីវ កេង បានមានប្រសាសន៍ថា ការបង្កើតប្រព័ន្ធសូចនាករនេះមានលក្ខណៈល្អត្រឹមត្រូវ និងមានអត្ថប្រយោជន៍ ច្រើនណាស់សម្រាប់ការកែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ និងសម្រាប់ការតាមដានការអនុវត្តការងាររបស់ក្រសួងស្ថាប័នពាក់ព័ន្ធ កែលំអរនូវចំណុចខ្វះខាតរបស់ស្ថាប័ន ធ្វើអោយស្ថាប័ននោះបំពេញ អាណត្តិរបស់ខ្លួនបានប្រសើរ ។

ជាបញ្ចប់ឯកឧត្តមប្រធានបានធ្វើការបូកសរុប ដោយកោតសរសើរចំពោះ សមាជិកក្រុមការងារជាន់ខ្ពស់ផ្នែក IMS និងអ្នកផ្តល់ជំនួយពាក់ព័ន្ធទាំងអស់ ដែលបានផ្តល់ការឧបត្ថម្ភគាំទ្រ ដល់ការកែទម្រង់ច្បាប់ និងតុលាការ ក្នុងពេលកន្លងមកក៏ដូចក្នុងពេលជាបន្តទៅមុខ និងជាពិសេសក្នុងពេលនេះ ដែលបានផ្តល់ការឯកភាព ចំពោះគោលការណ៍នៃការរៀបចំសូចនាករ ដើម្បីបានជាមូលដ្ឋានក្នុងការរៀបចំការងារ និងយន្តការពាក់ព័ន្ធផ្សេងៗ ទៀតសម្រាប់តាមដានកែលំអការកែទម្រង់អោយបាន កាន់តែប្រសើរឡើង ។ ឯកឧត្តមបានបញ្ជាក់ជា ចុងក្រោយថា ចាប់ពីពេលនេះ គម្រោង IMS នេះនឹងចូលទៅក្នុងដំណាក់កាលទីពីរហើយ គឺជាដំណាក់កាលអនុវត្ត ។

អង្គប្រជុំបានប្រព្រឹត្តទៅដោយរលូន ហើយបានបញ្ចប់នៅម៉ោងដប់ពីរគត់ នាថ្ងៃខែឆ្នាំដដែល ។

បានឃើញ និងឯកភាព

ជ.ប្រធានអង្គប្រជុំ　　　　　　　　　　　　　　អ្នកធ្វើរបាយការណ៍

សួង លាងហៃ　　　　　　　　　　　　ស៊ុន សិរីវុធ　　　សេង វ៉ាន់ដា